ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៥៤៧
ចុះថ្ងៃទី១៣/០៦/២០១៣
សាលដីកា
លេខ : ៧៥ ក្រIV ច
ចុះថ្ងៃទី ២៧/១១/២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើ តាមក្រិត្យលេខ: ០៦ក្រ ចុះថ្ងៃទី ០៨.០២.១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៧/១១/២០១៣ ដោយមាន ៖

### សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ : ៥៤៧ ចុះថ្ងៃទី១៣/០៦/២០១៣ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted] សេរីរាជ ភេទប្រុស ឆ្នាំកំណើត១៩៩៣ អាយុ២០ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតនៅភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ លំនៅសព្វថ្ងៃភូមិ [redacted] ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។

-ចាប់ខ្លួននៅថ្ងៃទី១០.១០.២០១២ និងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកំពត តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:៨៧៥ ព.១ ចុះថ្ងៃទី១៣.១០.២០១២ ។

២-ជនជាប់ចោទឈ្មោះ [redacted] អួច ភេទប្រុស ឆ្នាំកំណើត១៩៨៦ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ននៅភូ[redacted] ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។ "គេចខ្លួន" ។

- ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ:៤៥២ ព្រ.ទ ចុះថ្ងៃទី២០.១១.២០១២ ។

៣- ជនជាប់ចោទឈ្មោះ [redacted] រ៉ង ភេទប្រុស ឆ្នាំកំណើត១៩៩២ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតនៅភូមិព្រៃថ្កោ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ន[redacted] ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។ "គេចខ្លួន"

- ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ:៤៥៤ ព្រ.ទ ប ចុះថ្ងៃទី២០.១១. ២០១ ២។

៤- ជនជាប់ចោទឈ្មោះ [redacted] ទូច ហៅ ទេវ ភេទប្រុស ឆ្នាំកំណើត១៩៩២ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតភូមិព្រៃថ្កោ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្នភូមិព្រៃថ្កោ [redacted] ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។ "គេចខ្លួន"

- ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ:៤៥៣ ព្រ.ទ ចុះថ្ងៃទី២០.១១.២០១២ ។

-ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិព្រៃថ្កោ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

- ដើមបណ្តឹងរដ្ឋប្បវេណី :

១- ឈ្មោះ [redacted] រាជ អាយុ១៦ឆ្នាំ ភេទប្រុស សញ្ជាតិខ្មែរ មុខរបរសិស្ស ។ ទីកន្លែងកំណើតនៅភូមិត្រពាំងស្រង៉ែ ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត ។ អាស័យដ្ឋានបច្ចុប្បន្ននៅ[redacted]ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរនៅផ្ទះ នៅលីវ ។ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" និតិជន ។

២- ឈ្មោះ [redacted] កញ្ញារិទ្ធ អាយុ១៩ឆ្នាំ ភេទប្រុស សញ្ជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតនៅភូមិត្រពាំងកំភ្លាញ ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅសព្វថ្ងៃភូមិត្រពាំងកំភ្លាញ ឃុំអង្គភ្នំតូច ស្រុកអង្គរជ័យ ខេត្តកំពត ។

## <u>ឯរឿងហេតុមានដូចតទៅ</u> ៖

កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ វេលាម៉ោង១៦:៣០នាទី មានករណីប្រើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស "វាយតប់មានគ្នាច្រើន" កើតឡើងនៅភូមិព្រៃថ្កោ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ប្រព្រឹត្តដោយជនសង្ស័យ០៤នាក់ មានឈ្មោះ [redacted] សេរីរាជ, ឈ្មោះ [redacted] ទូច, ឈ្មោះ [redacted] រ៉ង និងឈ្មោះ [redacted] អួច បានធ្វើសកម្មភាពដោយប្រើដំបង និងដុំថ្ម ស្ទាក់វាយលើក្រុមជនរងគ្រោះចំនួន០៣នាក់ មានឈ្មោះ [redacted] រាជ, ឈ្មោះ [redacted] កញ្ញារិទ្ធ និងឈ្មោះ [redacted] ប៊ុនណាត ដែលកំពុងជិះម៉ូតូតាមផ្លូវបណ្តាលឱ្យឈ្មោះ [redacted] រាជ មានរបួស ។ ទំនាស់កើតឡើងដោយសារតែក្រុមរបស់ឈ្មោះ [redacted] សេរីរាជ ខឹងនឹងក្រុមឈ្មោះ [redacted] រាជ ជិះម៉ូតូវ៉ាក្នុងល្បឿនលឿន ។ ក្រោយកើតហេតុជនរងគ្រោះមានការប្តឹងសមត្ថកិច្ចនគរបាល ចាប់ខ្លួនបានឈ្មោះ [redacted] សេរីរាជ រីឯបក្សពួកផ្សេងទៀតរត់គេចខ្លួន ។

២៣២

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ២៣ "ខ" ចុះថ្ងៃទី១០.០៤.២០១៣ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោសៈ

ក.ឈ្មោះ [redacted] អួច ភេទប្រុស ឆ្នាំកំណើត១៩៨៦ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅសព្វថ្ងៃភូមិ[redacted] ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។ "គេចខ្លួន"

ខ.ឈ្មោះ [redacted] វ៉ង ភេទប្រុស ឆ្នាំកំណើត១៩៩២ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។ "គេចខ្លួន"

- ដាក់ពន្ធនាគារម្នាក់ៗកំណត់**២ឆ្នាំ(ពីរឆ្នាំ)** ពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ។ ប្រព្រឹត្តនៅភូមិភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

២.ឱ្យឈ្មោះ៖

ក.ឈ្មោះ [redacted] សេរីរាជ ភេទប្រុស ឆ្នាំកំណើត១៩៩៣ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ននៅ[redacted] ស្រុកអង្គរជ័យ ខេត្តកំពត ។ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ទោសពីមុនគ្មាន ។

ខ.ឈ្មោះ [redacted] ទូច ហៅ **ទេវ** ភេទប្រុស ឆ្នាំកំណើត១៩៩២ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ។ ទីកន្លែងកំណើតនៅភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត ។ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃផ្តៅ [redacted] ខេត្តកំពត ។ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ[redacted] ទោសពីមុនគ្មាន ។ **"គេចខ្លួន"**

រួចខ្លួនពីបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ។ អង្គហេតុចោទប្រកាន់ ប្រព្រឹត្តនៅភូមិព្រៃផ្តៅ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ៤៧៨ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពត ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ។

៣. ឱ្យឈ្មោះ [redacted] អួច និងឈ្មោះ [redacted] វ៉ង រួមគ្នាបង់សំណងជម្ងឺចិត្តជាប្រាក់ចំនួន១,២០០,០០០រៀល(មួយលានពីរសែនរៀល) មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] រាជ ។ បណ្តឹងទាមទារសុំលើសពីនេះបដិសេធចោល ។

៤. បដិសេធចោលបណ្តឹងទាមទារជម្ងឺចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កញ្ញារិទ្ធ។

៥. ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] អួច និងឈ្មោះ [redacted] វ៉ង ដែលមានសាវតារជាតិដូចខាងលើ និងយកមកឃុំខ្លួនក្នុងពន្ធនាគារតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ។

៦. ឱ្យបញ្ឈប់ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ[redacted] ឡូច ហៅ ទេវ ដែលត្រូវបានចេញដោយចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ:៤៥៣ ព្រ.ទ ចុះថ្ងៃទី២០.១១.២០១២។

៧. បង្គាប់ឱ្យដោះលែងឈ្មោះ[redacted] សេរីរាជ មានសេរីភាពវិញ ។

៨. សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សេរីរាជ។ កំបាំងមុខជនជាប់ចោទឈ្មោះ[redacted] អ្លូច ឈ្មោះ [redacted] រ៉ង ឈ្មោះ[redacted] ឡូច និងដើមបណ្តឹងរដ្ឋប្បវេណី ។

- បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ របស់ព្រះរាជអាជ្ញារង [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៣ “ខ” ចុះថ្ងៃទី១០-០៤-២០១៣ ត្រង់ចំណុចទី២ នៃសេចក្តីសម្រេច ។

**បានឃើញ** របាយការណ៍រឿង របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី០២/១០/២០១៣។

**បានឃើញ** សេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៨/១០/២០១៣។

នាពេលសវនាការ

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្តី
- អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted] សេរីរាជ ។
- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រាជ ។
- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]កញ្ញារិទ្ធ ។
- តំណាងមហាអយ្យការសន្និដ្ឋានថា : យល់ឃើញថា សំអាងហេតុរបស់សាលាដំបូងខេត្តកំពតមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ
- ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>**សំអាងហេតុ**</u>

យល់ឃើញថា

២៣៨

១/ ពាក្យបណ្ដឹងឧទ្ធរណ៍របស់លោកព្រះរាជអាជ្ញារង [redacted] ចុះថ្ងៃទី១១/០៤/២០១៣ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៣ “ខ” ចុះថ្ងៃទី១០/០៤/២០១៣ របស់សាលាដំបូងខេត្តកំពត ត្រង់ចំណុចទី២ នៃសេចក្ដីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២/ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សេរីរាជ នៅដំណាក់កាលអយ្យការថា : ខ្លួនមិនបានចូលរួមវាយគេទេ ហើយក៏មិនបានយកដុំថ្មទៅគប់លើម៉ូតូគេដែរ ថ្ងៃនោះ ខ្លួនមានគ្នា៤នាក់បានជិះម៉ូតូដេញតាមពួកគេ ប៉ុន្តែឈ្មោះ អ្នួច និងឈ្មោះ វ័ង បានឲ្យខ្លួន និងឈ្មោះ តេវ ជិះម៉ូតូត្រលប់មកផ្ទះវិញ ពេលនោះពួកខ្លួនទាំង២នាក់មកផ្ទះវិញ (ឯកសារលេខ ១៣) ។ ចម្លើយរបស់ជនជាប់ចោទរូបនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ជនរងគ្រោះ [redacted] រាជ ដែលបានឆ្លើយនៅមុខចៅក្រមស៊ើបសួរថា : ពួកវាមានគ្នា៤នាក់ ចូលមកវាយខ្លួន២នាក់ ឯ២នាក់ទៀតអង្គុយលើម៉ូតូ ៤នាក់នោះ មាន៣នាក់ខ្លួនមិនស្គាល់ឈ្មោះទេ ស្គាល់ម្នាក់ ដែលសមត្ថកិច្ចចាប់បានឈ្មោះ [redacted] សេរីរាជ ហើយឈ្មោះ [redacted] សេរីរាជ មិនបានមកវាយខ្លួនទេ គឺអង្គុយលើម៉ូតូ (ឯកសារលេខ ១៥) ។

តាមចម្លើយបំភ្លឺរបស់ជនជាប់ចោទ [redacted] សេរីរាជ និងចម្លើយជនរងគ្រោះ [redacted] រាជ ខាងលើ អាចឲ្យក្រុមប្រឹក្សាជឿបានថា ជនជាប់ចោទឈ្មោះ [redacted] សេរីរាជ និងឈ្មោះ [redacted] ទូច ហៅ ទេវ ពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់នោះទេ គឺមានតែជនជាប់ចោទឈ្មោះ [redacted] អ្នួច និងឈ្មោះ [redacted] វ័ង ប៉ុណ្ណោះ ។

៣/ តំណាងមហាអយ្យការ បានសន្និដ្ឋាននាសវនាការសាលាឧទ្ធរណ៍នេះ ដោយឯកភាពលើការសម្រេចរបស់សាលាដំបូង ហើយសុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ ។ ចំណុចនេះ ក្រុមប្រឹក្សាគប្បីពិចារណាតាមច្បាប់ ។

៤/ សំអាងហេតុក្នុងសាលក្រមព្រហ្មទណ្ឌលេខ ២៣ “ខ” របស់សាលាដំបូងខេត្តកំពតដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាពនឹងសំអាងហេតុរបស់សាលាដំបូង ដូច្នេះសាលាឧទ្ធរណ៍មិនចាំបាច់លើកយកមកសំអាងជាថ្មីទៀតទេ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១/ ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់លោកព្រះរាជអាជ្ញារង [redacted] ចុះថ្ងៃទី១១/០៤/២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២/ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៧៥ ចុះថ្ងៃទី១៣/១០/២០១២ របស់សាលាដំបូងខេត្តកំពត ទុកជាបានការដដែល។

២៣៥

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ កំបាំងមុខជនជាប់ចោទ។

បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] , [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៤
ក្រឡាបញ្ជី
[redacted]

២៣៦